**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងរវាងនាយិកាក្រុមហ៊ុនភោជនីយដ្ឋានចាន់រីទ្រីនិងតំណាងកម្មករនិយោជិក ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ២០២០វេលាម៉ោង ៩ និង ៣០នាទី នៅក្នុងក្រុមហ៊ុនភោជនីយដ្ឋានចាន់រីទ្រីមានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិក។

នៅក្នុងអង្គប្រជុំនេះនាយិកាក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិកទាំងអស់អំពីស្ថានភាពបច្ចុប្បន្នរបស់ក្រុមហ៊ុនថា ដោយសារការរីករាលដាលនិងចម្លងនៃជំងឺរលាកសួតប្រភេទថ្មីCovid-19ដែលជាហេតុបណ្តាលអោយមានផលប៉ះពាល់ដល់សេដ្ឋកិច្ចពិភពលោកហើយក៏ជាហេតុដែលធ្វើអោយក្រុមហ៊ុនទទួលរងការខាតបង់ មិនមានប្រាក់ចំណូលសំរាប់ទ្រទ្រង់ប្រតិបត្តិការណ៍បន្តទៀតបាន។

ហេតុដូចនេះក្រុមហ៊ុនបានសំរេចចិត្តធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិកទាំងអស់ ចំនួន៦០នាក់(ស្រី១៣នាក់)រយៈពេល៥៨ថ្ងៃដោយគិតចាប់ពីថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ រហូតដល់ទី៣១ ខែធ្នូ ឆ្នាំ២០២០នៅក្នុងកំឡុងពេលនៃការព្យួរនេះកម្មករនិយោជិកបានទទួលស្គាល់នូវការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឈ្នួលចំនួន៦០ដុល្លារអាមេរិកក្នុងមួយខែសំរាប់កម្មករនិយោជិកម្នាក់ៗ។ អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១០និង៣០នាទីនាថ្ងៃខែឆ្នាំដដែល ដោយសារភាគីទាំងសងខាងមានការស្និទ្ធស្នាលនិងយោគយល់គ្នាក្រោមស្មារតីទទួលនិងសហការគ្នាយ៉ាងរលូន។

ថ្ងៃពុធ៤រោចខែកត្តិក ឆ្នាំជូតទោស័ក ព.ស២៥៦៤
សៀមរាប ថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ២០២០

ហត្ថលេខា និងត្រា នាយិកា

CHANREY TREE
KINGDOM OF CAMBODIA

ជុនតាប់

តំណាងកម្មករនិយោជិក